**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តតាកែវ**

# របាយការណ៍

# បូកសរុបលទ្ធផលការងារក្រុមប្រឹក្សាខេត្តតាកែវ
# អាណត្តិទី៣ (២០១៩-២០២៣)
# របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតាកែវ

# ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតាកែវ

**សូមគោរពជូន**

**ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្ត**

**កម្មវត្ថុ**: ស្តីពីរបាយការណ៍ បូកសរុបលទ្ធផលការងារក្រុមប្រឹក្សាខេត្តតាកែវអាណត្តិទី៣ (២០១៩-២០២៣) របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតាកែវ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជូន**ឯកឧត្តម**មេត្តាជ្រាបថា : នៅក្នុងរយៈពេលប្រាំឆ្នាំនៃលទ្ធផលការងារក្រុមប្រឹក្សាខេត្តតាកែវអាណត្តិទី៣ គឺពីឆ្នាំ២០១៩ ដល់ ឆ្នាំ២០២៣ នេះមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតាកែវ បានបំពេញភារកិច្ច និងសម្រេចបានលទ្ធផលការងារដែលមាននៅក្នុងចំណុចនៃការអនុវត្តការងារហិរញ្ញវត្ថុ របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានដូចខាងក្រោម ÷

**២.១.៦. ការងារហិរញ្ញវត្ថុ របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**១.របាយការណ៍ចំណូល-ចំណាយថវិកាថ្នាក់ជាតិ**

| ឆ្នាំ | ចំណូល | | អនុវត្តលើស ឬ ខ្វះ | សមាមាត្រ | ផ្សេងៗ |
|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | | | |
| 2019 | 2,518,100,000 | 5,645,729,595 | 3,127,629,595 | 224.0% | |
| 2020 | 515,300,000 | 745,412,707 | 230,112,707 | 145.0% | |
| 2021 | 537,800,000 | 1,007,279,960 | 469,479,960 | 187.3% | |
| 2022 | 524,200,000 | 1,020,848,682 | 496,648,682 | 194.7% | |
| 2023 | 590,700,000 | 590,824,435 | 124,435 | 100.0% | |
| សរុប | **4,686,100,000** | **9,010,095,379** | **4,323,995,379** | **192.0%** | |

| ឆ្នាំ | ចំណាយ | | ឥណទាននៅសល់ | សមាមាត្រ | ផ្សេងៗ |
|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | | | |
| 2019 | 268,910,384,000 | 262,774,100,766 | 6,136,283,234 | 98.0% | |
| 2020 | 285,341,800,000 | 269,743,628,891 | 15,598,171,109 | 95.0% | |
| 2021 | 232,484,600,000 | 217,589,174,358 | 14,895,425,642 | 92.9% | |
| 2022 | 234,452,600,000 | 229,423,886,739 | 5,028,713,261 | 98.6% | |
| 2023 | 253,218,200,000 | 251,518,249,812 | 1,699,950,188 | 98.5% | |
| សរុប | **1,274,407,584,000** | **1,231,049,040,566** | **43,358,543,434** | **97.0%** | |

## ២. របាយការណ៍ចំណូល-ចំណាយថវិការបស់រដ្ឋបាលក្រុង-ស្រុក

| ឆ្នាំ | ចំណូល | | អនុវត្តលើស ឬ ខ្វះ | សមាមាត្រ | ផ្សេងៗ |
|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | | | |
| 2019 | 14,804,180,000 | 14,619,136,670 | (185,043,330) | 99% | |
| 2020 | 14,486,000,000 | 14,318,212,772 | (167,787,228) | 99% | |
| 2021 | 21,120,400,000 | 22,772,534,766 | 1,652,134,766 | 108% | |
| 2022 | 24,718,230,000 | 26,698,671,770 | 1,980,441,770 | 108% | |
| 2023 | 28,548,540,000 | 29,503,989,800 | 955,449,800 | 103% | |
| សរុប | **103,677,350,000** | **107,912,545,778** | **4,235,195,778** | **106%** | |

| ឆ្នាំ | ចំណាយ | | ឥណទាននៅសល់ | សមាមាត្រ | ផ្សេងៗ |
|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | | | |
| 2019 | 14,804,180,000 | 14,263,891,837 | 540,288,163 | 96% | |
| 2020 | 14,486,000,000 | 13,839,241,417 | 646,758,583 | 96% | |
| 2021 | 22,899,610,000 | 21,667,576,758 | 1,232,033,242 | 95% | |

| | | | | | |
|---|---|---|---|---|---|
| 2022 | 26,971,230,000 | 25,959,332,370 | 1,011,897,630 | 96% | |
| 2023 | 30,170,540,000 | 28,910,917,996 | 1,259,622,004 | 96% | |
| សរុប | **109,331,560,000** | **104,640,960,378** | **4,690,599,622** | **96%** | |

## ៣. របាយការណ៍ចំណូល-ចំណាយថវិការបស់រដ្ឋបាលខេត្ត

| ឆ្នាំ | ចំណូល | | អនុវត្តលើស ឬ ខ្វះ | សមាមាត្រ | ផ្សេងៗ |
|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | | | |
| 2019 | 16,291,000,000 | 53,375,852,366 | 37,084,852,366 | 328% | |
| 2020 | 20,710,100,000 | 47,929,808,774 | 27,219,708,774 | 231% | |
| 2021 | 21,663,000,000 | 49,545,254,980 | 27,882,254,980 | 229% | |
| 2022 | 28,148,000,000 | 75,237,832,357 | 47,089,832,357 | 267% | |
| 2023 | 36,464,000,000 | 120,764,010,163 | 84,300,010,163 | 331% | |
| សរុប | **123,276,100,000** | **346,852,758,640** | **223,576,658,640** | **330%** | |

| ឆ្នាំ | ចំណាយ | | ឥណទាននៅសល់ | សមាមាត្រ | ផ្សេងៗ |
|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | | | |
| 2019 | 44,223,600,000 | 43,997,761,910 | 225,838,090 | 99% | |
| 2020 | 39,249,100,000 | 37,022,662,248 | 2,226,437,752 | 94% | |
| 2021 | 60,257,200,000 | 60,033,618,675 | 223,581,325 | 100% | |
| 2022 | 61,848,000,000 | 61,686,612,495 | 161,387,505 | 100% | |
| 2023 | 117,988,000,000 | 116,611,340,395 | 1,376,659,605 | 99% | |
| សរុប | **323,565,900,000** | **319,351,995,723** | **4,213,904,277** | **99%** | |

៤.របាយការណ៍ចំណាយរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៩-២០២៣

-សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៩

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ | ស្ថានភាពឥទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រ |
|---|---|---|---|---|---|
| 60 | 467,600,000 | 467,600,000 | 464,295,525 | 3,304,475 | 99% |
| 61 | 523,200,000 | 523,200,000 | 520,938,900 | 2,261,100 | 100% |
| 64 | 542,500,000 | 542,500,000 | 533,104,184 | 9,395,816 | 98% |
| សរុប | **1,533,300,000** | **1,533,300,000** | **1,518,338,609** | **14,961,391** | **98%** |

-សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២០

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ | ស្ថានភាពឥទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រ |
|---|---|---|---|---|---|
| 60 | 321,300,000 | 321,300,000 | 303,837,578 | 17,462,422 | 94.6% |
| 61 | 529,000,000 | 529,000,000 | 482,778,253 | 46,221,747 | 91.3% |
| 64 | 586,400,000 | 586,400,000 | 559,620,000 | 26,780,000 | 95.4% |
| សរុប | **1,436,700,000** | **1,436,700,000** | **1,346,235,831** | **90,464,169** | **95.6%** |

-សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២១

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ | ស្ថានភាពឥទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រ |
|---|---|---|---|---|---|
| 60 | 282,200,000 | 282,200,000 | 270,154,770 | 12,045,230 | 96% |
| 61 | 547,000,000 | 547,000,000 | 533,223,264 | 13,776,736 | 97% |
| 64 | 571,200,000 | 604,553,000 | 588,632,500 | 15,920,000 | 97% |
| 63 | 600,000 | 600,000 | 600,000 | | 100% |
| សរុប | **1,401,000,000** | **1,434,353,000** | **1,392,610,534** | **41,741,966** | **98%** |

-សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ | ស្ថានភាពឥទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រ |
|---|---|---|---|---|---|
| 60 | 286,200,000 | 286,200,000 | 275,629,130 | 10,570,870 | 96% |
| 61 | 547,000,000 | 547,000,000 | 546,143,030 | 856,970 | 100% |
| 64 | 600,800,000 | 600,800,000 | 588,000,000 | 12,800,000 | 98% |
| 63 | 600,000 | 600,000 | 600,000 | | 100% |
| សរុប | **1,434,600,000** | **1,434,600,000** | **1,410,372,160** | **24,227,840** | **99%** |

-សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ | ស្ថានភាពឥណទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រ |
|---|---|---|---|---|---|
| 60 | 295,200,000 | 295,200,000 | 294,123,030 | 1,076,970 | 100% |
| 61 | 553,900,000 | 573,900,000 | 569,926,250 | 3,973,750 | 99% |
| 64 | 653,300,000 | 653,300,000 | 626,640,000 | 26,660,000 | 96% |
| 63 | 600,000 | 600,000 | 600,000 | | 100% |
| សរុប | **1,503,000,000** | **1,523,000,000** | **1,491,289,280** | **31,710,720** | **99%** |

**៥.ការងារដែលត្រូវធ្វើបន្ត**

ការងារត្រូវធ្វើបន្តរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តតាកែវ មានដូចតទៅ÷

- បន្តអនុវត្តនូវអភិក្រមការងារ៤ប្រការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពង្រឹងតួនាទី ភារកិច្ចរបស់មន្ទីរ ឱ្យកាន់តែប្រសើរ
- បន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពីជំនាញលទ្ធកម្មសាធារណៈ មានទាំងនីតិវិធី និងវិធីសាស្រ្តលទ្ធកម្ម ការរៀបចំផែនការលទ្ធកម្ម ការរៀបចំរបាយការណ៍អនុវត្តកិច្ចលទ្ធកម្ម ដល់អង្គភាពលទ្ធកម្មរដ្ឋបាលក្រុង-ស្រុកទាំង១០ ដើម្បីឱ្យការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព ប្រសិទ្ធផល និងត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- បន្តពង្រឹងលើការងារគ្រប់គ្រងត្រួតពិនិត្យ និងតាមដានការអនុវត្តកិច្ចលទ្ធកម្មរបស់អង្គភាពលទ្ធកម្មរដ្ឋបាលក្រុង-ស្រុកដើម្បី ធានាឱ្យបាននូវលទ្ធផលកាន់តែល្អជាងឆ្នាំកន្លងៗមក ។
- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយណែនាំស្តីពីតម្រូវការនៃការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធFMIS ដល់ក្រុមលទ្ធកម្មតាមបណ្តាមន្ទីរជំនាញក៏ដូចជាអង្គភាពលទ្ធកម្មក្រុង ស្រុកទាំង១០នៃខេត្តតាកែវក្នុងគោលបំណងជម្រុញឱ្យមានការយកចិត្តទុកដាក់ខ្ពស់លើការងារដើម្បីសម្រេចបានទាន់ពេលវេលា ។
- រៀបចំវគ្គបណ្តុះបណ្តាលមន្ទីរជំនាញស្តីពីជំនាញក្នុងការចំណាយថវិកាឱ្យស្របតាមច្បាប់ និងការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាការកត់ត្រាលើអាណត្តិចំណាយ ដើម្បីឱ្យការអនុវត្តចំណាយកាន់តែមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ ។
- បន្តពង្រឹងលើការងារគ្រប់គ្រងតាមដាន និងការត្រួតពិនិត្យឯកសារចំណាយតាមមន្ទីរជំនាញនានាឱ្យបានត្រឹមត្រូវ ។
- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយណែនាំស្តីពីតម្រូវការនៃការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធFMISតាមបណ្តាមន្ទីរជំនាញក្នុងគោលបំណងជម្រុញឱ្យមានការយកចិត្តទុកដាក់ខ្ពស់លើការងារដើម្បីសម្រេចបានទាន់ពេលវេលា ។
- បន្តជំរុញការធ្វើបញ្ជីសារពើភណ្ឌ (តារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋ) ទូទាំងខេត្តតាកែវ ចំពោះអង្គភាពណាដែលធ្វើមិនទាន់រួចរាល់ ។

- បន្តបើកផ្តល់បង្កាន់ដៃបង់ប្រាក់ប្រភេទ១ និងប្រភេទ២ ជូនមន្ទីរ អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បន្តត្រួតពិនិត្យបញ្ជាក់ស្តីពីការកាត់ទុកប្រាក់រង្វាន់លើកទឹកចិត្តជូនដល់មន្ទីរ អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បន្តចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ចំពោះអាជីវករណាដែលមកសុំច្បាប់ត្រឹមត្រូវ។
- បន្តអនុវត្តផែនការសកម្មភាពទទួលប្រាក់ឧបត្ថមមុខងារក្រៅកែទម្រង់ប្រចាំឆ្នាំ។
- ពង្រឹងការគ្រប់គ្រងចំណាយថវិកាជាតិ ចំទិសដៅ និងសន្សំសំចៃ
- ពង្រឹងការវិភាជន៍ ការផ្ទេរ និង ការប្រើប្រាស់ធនធានមូលនិធិរបស់រដ្ឋបាលក្រុង-ស្រុក
- បង្កើនសមត្ថភាពគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅខេត្តតាកែវ
- គាំទ្រ និងសម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅខេត្តតាកែវ
- បន្តពង្រឹងណែនាំ និងជម្រុញការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ការចំណាយប្រាក់រង្វាន់ និងការធ្វើអាណត្តិនិយ័តកម្មតាមបណ្តាមន្ទីរពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

## ៦.បញ្ហាប្រឈមក្នុងការងារអនុវត្តកន្លងមក ឆ្នាំ២០១៩-២០២៣

- ម្ចាស់អចលនទ្រព្យមិនបានយកចិត្តទុកដាក់ស្នើសុំវាស់វែង
- ដីដែលចុះបញ្ជីស្ទួនគ្នាមិនបានស្នើសុំជម្រះអោយបានទាន់ពេលវេលា
- ដីដែលមានទំនាស់រាំរៃមិនមានចំណាត់ការ
- រាល់ការស្នើសុំជម្រះសម្ភារ និងសង្ហារឹមតាមប្រភេទមួយចំនួនមានតែក្នុងបញ្ជីសារពើភណ្ឌ
- ចំណេះដឹងរបស់មន្ត្រីទទួលបន្ទុកលើការងារលទ្ធកម្មសាធារណៈ នៅតាមអង្គភាពលទ្ធកម្មក្រុងស្រុកមួយចំនួននៅមានកម្រិត។
- អង្គភាពលទ្ធកម្មក្រុងស្រុកមួយចំនួនមិនយកចិត្តទុកដាក់លើការរៀបចំរបាយការណ៍អនុវត្តកិច្ចលទ្ធកម្ម ប្រចាំត្រីមាស ឆមាស និងឆ្នាំ ផ្ញើរមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតាកែវតាមកាលបរិច្ឆេទ កំណត់ ទោះបីមានការស្នើសុំក៏ដូចជារំលឹកច្រើនដងក៏ដោយ។
- រដ្ឋបាលក្រុង-ស្រុក ការស្នើសុំនិយ័តភាពថវិកាមិនបានទាន់ពេលវេលា
- ការធ្វើរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ មិនបានត្រឹមត្រូវ និងទាន់ពេលវេលា

## ៧.សំណើដំណោះស្រាយបញ្ហាប្រឈម

- សំណូមពរមន្ទីរ អង្គភាព ថ្នាក់មូលដ្ឋាន នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់ រៀបចំឯកសារស្នើសុំវាស់វែង
- សំណូមពរមន្ទីរ អង្គភាព ថ្នាក់មូលដ្ឋាន នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់ រៀបចំស្នើសុំតាមនិតិវិធីដើម្បីសុំជម្រះពីអង្គភាពមួយ ទៅអង្គភាពមួយ អោយបានច្បាស់លាស់ងាយស្រួល ចុះក្នុងបញ្ជីសារពើភណ្ឌឱ្យបានត្រឹមត្រូវ

- សំណូមពរមន្ទីរ អង្គភាព ថ្នាក់មូលដ្ឋាន នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់ អំពីដីដែលមានទំនាស់រ៉ាំរ៉ៃ សូមលើកសំណើទៅតាមនិតិវិធី ឱ្យស្របតាមអនុក្រិត លេខ៦៦ និង ប្រកាសលេខ០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សំណូមពរមន្ទីរ អង្គភាព ថ្នាក់មូលដ្ឋាន នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់ លើការស្នើសុំជម្រះ អោយស្របតាមប្រកាសលេខ០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សំណូមពរដល់អង្គភាពលទ្ធកម្មក្រុង-ស្រុកមួយចំនួនត្រូវយកចិត្តទុកដាក់លើការរៀបចំរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ ផ្ញើរមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតាកែវតាមកាលបរិច្ឆេទកំណត់ ។
- សំណូមពរដល់រដ្ឋបាលក្រុង-ស្រុក ធ្វើការស្នើសុំនិយ័តភាពថវិកាឱ្យបានទាន់ពេលវេលា
- សំណូមពរការធ្វើរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ឱបានត្រឹមត្រូវ និងទាន់ពេលវេលា
- សំណូមពរមន្ត្រីទទួលបន្ទុកលើការងារលទ្ធកម្មសាធារណៈ នៅតាមអង្គភាពលទ្ធកម្មក្រុង-ស្រុកមួយចំនួន មិនត្រូវផ្លាស់ ប្តូរភ្លាមៗ រងចាំមានមន្ត្រីទទួលបន្ទុកថ្មីបានបណ្តុះបណ្តាលច្បាស់លាស់ជាមុនសិន

**៨.សេចក្តីសន្និដ្ឋាន**

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតាកែវ បានបំពេញនូវតួនាទីរបស់ខ្លួនយ៉ាងល្អប្រសើរក្នុងនាមជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងមូលដ្ឋាន ។ ទោះបីសមត្ថភាពបច្ចេកទេស និងបទពិសោធន៍ការងារនៅមានកម្រិតលើការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ពិសេសការអនុវត្តថវិកាកម្មវិធី ដែលជាចក្ខុវិស័យរបស់ក្រសួង និងរាជរដ្ឋាភិបាលនៅជួបបញ្ហាប្រឈម ហើយដែលត្រូវបន្តដោះស្រាយបន្ថែមទៀត ក៏មន្ត្រីរាជការក្នុងអង្គភាព បានខិតខំបំពេញភារកិច្ច រៀនផង អនុវត្តន៍ជាក់ស្តែងផង ចូលរួមចំណែកអនុវត្តគោលនយោបាយរបស់ក្រសួងទទួលបានលទ្ធផលល្អប្រសើរជាបណ្តើរៗ ។

មន្ទីរមានជំនឿយ៉ាងមុតមាំ និងបន្តអនុវត្តបំពេញនូវតួនាទីរបស់ខ្លួនដើម្បីសម្រេចលទ្ធផលល្អប្រសើរបន្ថែមទៀត ពិសេសការសម្រេចបាននូវការប្រមូលចំណូលមិនមែនសារពើពន្ធ ការត្រួតពិនិត្យចំណាយថវិកាមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សន្សំសំចៃ និងចំទិសដៅ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមអភិបាលខេត្ត** មេត្តាជ្រាបជារបាយការណ៍ដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអភិបាលខេត្ត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ថ្ងៃចន្ទ ១៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

តាកែវ,ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២៤

**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត**

**ហោ បុណ្ណវឌ្ឍន៍**